# បទពិសោធន៍បន្សុទ្ធពូជស្រូវ





**ទិដ្ឋភាពដំណាំស្រូវ បវស នៅពេលកំពុងលូតលាស់**

**លោកអ៊ំ ហ៊្សួយ ប៊ិន ជាកសិកររស់នៅភូមិចំបក់ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ។ គាត់ជាកសិករសហការជាមួយអង្គការសេដាក ចាប់តាំងពីខែមិថុនា ឆ្នាំ ២០០៨ ។ កន្លងមកគាត់បានទទួលការបណ្តុះបណ្តាលបច្ចេកទេសជាច្រើនពីអង្គការសេដាក ដូចជា ប.វ.ស ការបន្សុទ្ធពូជស្រូវ សួនដំណាំលក្ខណៈគ្រួសារ ការចិញ្ចឹមមាន់តាមគោលការណ៍ធម្មជាតិ ការធ្វើជីកំប៉ុស្ត និងការសន្សំប្រាក់ជាដើម ។ ក្រោយពីបានទទួលចំណេះដឹងស្តីពីការបន្សុទ្ធពូជស្រូវ គាត់បានធ្វើការសាកល្បងរហូតទទួលបានជោគជ័យ ដែលបទពិ-សោធន៍នេះ មានបង្ហាញជូនដូចខាងក្រោម ៖**

## ១. ការត្រៀមយកពូជស្រូវទៅដាក់ដាំ

គាត់ជ្រើសរើសប្រភេទពូជស្រូវ ឈ្មោះ ស្រូវសុម៉ាលី ដែលមានទំងន់ ១៥ គីឡូក្រាម ថ្លឹងទាំងកួរ ។

- មុននឹងដាំ គាត់បានយកកួរស្រូវទៅញីឲ្យជ្រុះគ្រាប់ រួចយកទៅអុំពោយវាឲ្យជ្រះល្អ
- បន្ទាប់មកយកគ្រាប់ស្រូវទៅកូរជាមួយទឹក រួចស្រង់យកគ្រាប់ណាស្កៀតចេញ។
- រួចយកស្លឹកស្តៅហាន់ឲ្យល្អិត បុកឲ្យទក់ រួចយកគ្រាប់ស្រូវទៅដាក់ត្រាំនៅក្នុងទឹកស្តៅ មួយយប់ ហើយស្រង់មកផ្អាប់មួយយប់ ។ (សំគាល់: ស្រូវពូជ ១០ គីឡូក្រាម ស្លឹកស្តៅចំនួន ០,៥ គីឡូក្រាម។)

## ២. របៀបជ្រើសរើសពូជស្រូវ

- ជ្រើសរើសគុម្ពស្រូវដែលមានចំងាយពីភ្លឺស្រែប្រមាណជា ២ ទៅ ៣ ម៉ែត្រ
- ជ្រើសរើសដើមនៅតាមគុម្ពស្រូវណាដែលមានផ្លែល្អ គ្រាប់ពេញថ្លោស និងកួរវែង។
- ជ្រើសរើសដើមណា ដែលមានស្លឹកទង់ជ័យប្រវែងកួរស្រូវ ។ លៃយ៉ាងណាកុំឲ្យខ្ពីជាងព្រោះអាចធ្វើឲ្យផលបានតិច

- ក្រោយពីច្រូតរួចយកកួរស្រូវដែលកាត់រួចទៅដាក់ហាលថ្ងៃឱ្យស្ងួត  យកកួរស្រូវដែលស្ងួតទៅចងព្យួររក្សាទុក ។

### ៣. ការថែរក្សាទុកដាក់ពូជស្រូវ

ក្រោយពីជ្រើសរើសពូជស្រូវបានល្អហើយ គាត់បានយកទៅរក្សាទុកនៅកន្លែងដែលមានបរិយាកាសល្អ ដូចជានៅក្រោមផ្ទះផុតពីដៃក្មេង ចងព្យួរនៅចង្ក្រានបាយ ជង្រុកស្រូវលើផ្ទះ ឬក្នុងផ្ទះ ដែលអាចមានខ្យល់ចេញចូលបានល្អ។



**សកម្មភាពរក្សាទុកពូជស្រូវដោយចងព្យួរនៅតាមរនូតផ្ទះ**

### ៤. ចំណាប់អារម្មណ៍

ក្រោយពីការជ្រើសរើសពូជស្រូវនេះហើយ គាត់សំគាល់ឃើញថាទិន្នផលស្រូវរបស់គាត់មានការកើនឡើងជារៀងរាល់ឆ្នាំ ដោយក្នុងផ្ទៃដី ៥ អារ ទិន្នផលពីមុនទទួលបាន ៣៧០ គីឡូក្រាម រហូតមកដល់ឆ្នាំ ២០១០ កន្លងទៅនេះទិន្នផលសរុប គាត់ទទួលបានប្រមាណជា ៥៩០ គីឡូក្រាម នៅលើផ្ទៃដី ៥ អារដដែល។ នៅឆ្នាំខាងមុខ គាត់មានជំនឿជឿជាក់ថា ការជ្រើសរើសពូជស្រូវ បានល្អជារៀងរាល់ឆ្នាំ អាចធ្វើឲ្យទិន្នផលស្រូវខ្ពស់ មានពណ៌ល្អ រសជាតិឆ្ងាញ់ និងក្លិនក្រអូប។

**សរុបមក បច្ចេកទេសសំខាន់ៗ ក្នុងការសម្រិតសម្រាំងពូជស្រូវមាន៖**

- ត្រូវជ្រើសរើសស្រូវដែលនៅឆ្ងាយពីភ្លឺចម្ងាយឲ្យបាន ២-៣ ម៉ែត្រ
- ជ្រើសរើសដើមនៅក្នុងគុម្ពស្រូវណាដែលថ្លោសជាងគេ និងមានផ្លែល្អ
- ជ្រើសរើសដើមដែលមានស្លឹកទង់ជ័យប្រវែងកួរស្រូវ
- រក្សាទុកកួរស្រូវនៅកន្លែងដែលមានបរិយាកាសល្អ មានខ្យល់ចេញចូល និងផុតពីដៃក្មេង
- មុនយកគ្រាប់ស្រូវទៅសាបត្រូវញីគ្រាប់ស្រូវឲ្យជ្រុះពីកួរ  យកទៅអុំរោយឲ្យស្អាតមុនដាក់ត្រាំទឹក
- ត្រាំគ្រាប់ស្រូវជាមួយស្លឹកស្ដៅមុនយកទៅសាប ។